# គណបក្ស សិទ្ធិមនុស្ស
## HUMAN RIGHTS PARTY

បំរើ ការពារ កសាង

លេខ.០០០១/០៩ .គ.ស.ម

ធ្វើនៅភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩

# សេចក្តីថ្លែងការណ៍

សមាជិកសភា៣រូប រួមជាមួយប្រតិភូ និងក្រុមការងាររបស់គណបក្សសិទ្ធិមនុស្ស បានចុះទៅសួរសុខទុក្ខ និងផ្តល់ជំនួយសប្បុរសធម៌ដល់ទាហានដែលឈរជើងនៅលើភ្នំប្រាសាទព្រះវិហារ កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០០៩ ប៉ុន្តែត្រូវបានរាំងដោយទាហានយាមនៅជើងភ្នំព្រះវិហារ ទោះបីមានការបង្ហាញលិខិតបេសកកម្មពីនាក់តំណាងរាស្ត្រ ដែលចុះហត្ថលេខាដោយប្រធានរដ្ឋសភាក៏ដោយ ក៏ពួកគេមិនឱ្យឡើងទៅកាន់ប្រាសាទព្រះវិហារឡើយ ។ នេះសរបញ្ជាក់ថាលិខិតបេសកកម្មគ្មានប្រសិទ្ធិភាពរបស់ប្រធានរដ្ឋសភាដោយពួកគេមិនគោរព ។

យើងសង្កេតឃើញថា នេះគឺជាលេសដែលរដ្ឋាភិបាលកម្ពុជា មានចេតនារារាំងមិនអនុញ្ញាតឱ្យសមាជិកសភារបស់គណបក្សសិទ្ធិមនុស្ស ចូលសួរសុខទុក្ខយុទ្ធជន និងផ្តល់ជំនួយសប្បុរសធម៌ដល់ពួកគេហើយរដ្ឋាភិបាលកម្ពុជាគ្មានបំណងពិតប្រាកដក្នុងការរកដំណោះស្រាយណាមួយជូនប្រទេសជាតិ ស្របតាមផ្លូវច្បាប់អន្តរជាតិនោះទេ ផ្ទុយទៅវិញគ្រាន់តែលេសសំរាប់បញ្ចេញសកម្មភាពតែបក្សពួកខ្លួន ដើម្បីកេងចំណេញនយោបាយតែប៉ុណ្ណោះ ។ **ទឹកដីខ្មែរ ប្រាសាទខ្មែរ ជារបស់ខ្មែរ មិនមែនជារបស់បុគ្គលណាម្នាក់ទេ** ដូច្នេះមិនថា បុគ្គលណា គណបក្សណា ឱ្យតែមានមនសិការស្នេហាជាតិពិតចង់ទៅទីនោះត្រូវតែរដ្ឋាភិបាលធានាសុវត្ថិភាព ។ គណបក្សសិទ្ធិមនុស្សដែលជាគណបក្សមិនរណបមានបំណងសួរសុខទុក្ខ លើកទឹកចិត្ត និងនាំជំនួយសប្បុរសជនប្រគេនដល់ព្រះសង្ឃ ចែកជូនដល់យុទ្ធជនការពារប្រាសាទព្រះវិហារ និងបងប្អូនប្រជាពលរដ្ឋបែរជាមិនត្រូវបានអនុញ្ញាតទៅវិញ ។

ក្នុងនាមសមាជិកសភាគណបក្សសិទ្ធិមនុស្ស សូមសំដែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះរដ្ឋាភិបាលកម្ពុជាដែលមានចេតនាមិនល្អរារាំងចំពោះគណបក្សមិនមែនរដ្ឋាភិបាលដែលមានអាសនៈនៅក្នុងរដ្ឋសភា ។ នៅក្នុងសភាទាល់តែមានសមាជិកសភាយ៉ាងតិច១០រូប ទើបមានសិទ្ធិនិយាយ ឬបញ្ចេញមតិ ចុះការឡើងទៅកាន់ប្រាសាទព្រះវិហារត្រូវការចំនួនសមាជិកសភាយ៉ាងតិច១០រូបដែរឬ ទើបអាចឡើងបាន ?

*សំរាប់ពត៌មានបន្ថែមសូមទំនាក់ទំនង*
*ទូរស័ព្ទលេខ : ០១៦ ៤៣៥ ១០៦*

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 12 539 999 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.com